ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

លេខ ០០៧ ស.អ.យ.

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែមករា ឆ្នាំ ២០១០

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ: 451
ថ្ងៃទី 25-3-...
បញ្ជូន...

# សេចក្តីណែនាំ

## ស្តីពី

## ការពង្រឹងការអនុវត្តន៍របបសោធនជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ

យោងសារាចរណែនាំអន្តរក្រសួងលេខ ០៩ សរច.ណន ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការបើកប្រាក់សោធនជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ និងយោងលិខិតលេខ ៦៧៤៥ សហវ.ថ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់កិច្ចសហការ ដើម្បីពង្រឹងការអនុវត្តន៍របបសោធន។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សូមធ្វើការណែនាំដូចខាងក្រោម ៖

១ - គ្រប់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី-ខេត្ត ត្រូវជំរុញការរៀបចំបែបបទលើកសំណើសុំថវិកាប្រចាំខែលើកដំបូងជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ឱ្យបានទាន់ពេលវេលា និងឆាប់រហ័សបំផុត ស្របតាមគោលការណ៍ដែលបានកំណត់ ដោយសហការជាមួយមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រាជធានី-ខេត្ត។

២ - គ្រប់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី-ខេត្ត ត្រូវសហការជាមួយមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រាជធានី-ខេត្ត ដើម្បីជំរុញការបើកប្រាក់សោធនប្រចាំខែលើកដំបូង និងខែបន្តបន្ទាប់ ជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ឱ្យបានឆាប់រហ័សបំផុត ជៀសវាងបាតុភាពដែលអាចកើតមានឡើងដោយថាហេតុ។

៣ - គ្រប់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី-ខេត្ត ត្រូវជំរុញការរៀបចំបែបបទកែសម្រួលសន្ទស្សន៍ប្រាក់សោធនជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ឱ្យបានទាន់ពេលវេលា។

៤ - គ្រប់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី-ខេត្ត ត្រូវអនុវត្តសារាចរណែនាំអន្តរក្រសួងលេខ ០៩ សរច.ណន ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការបើកប្រាក់សោធនជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ឱ្យបានម៉ឺងម៉ាត់ និងលិខិតលេខ ៦៧៤៥ សហវ.ថ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់កិច្ចសហការ ដើម្បីពង្រឹងការអនុវត្តន៍របបសោធន។

គ្រប់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី-ខេត្ត ត្រូវអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះ ដោយស្មារតីទទួលខុសត្រូវខ្ពស់ និងមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រី

អ៊ិត សំហេង

**ចម្លងជូន :**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី-ខេត្ត

"ដើម្បីជូនជ្រាប"
- គ្រប់អង្គភាពក្រោមឱវាទក្រសួង ស.អ.យ

"ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ